លេខ/ No:D94/I

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**Royaume du Cambodge**

**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Chambres Extraordinaires au sein
des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

**សំណុំរឿងព្រហ្មទណ្ឌ**

**Criminal Case File /Dossier pénal**

**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**

**លេខ/No: 001/18-07-2007-ECCC-OCIJ**

# ដីកាសម្រេចលើពាក្យសុំកិច្ចស៊ើបសួរ

## Ordonnance sur demandes d'actes d'instruction

## Order concerning Requests for Investigative Actions

យើង **យូ ប៊ុនឡេង** និង **Marcel Lemonde** (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំ-ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ភេទប្រុស កើតថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ១៩៤២

ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញបណ្តឹងសុំរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០០៨ ស្នើសុំថា **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** គួរត្រូវបានចោទប្រកាន់ពីបទមនុស្សឃាត (មាត្រា៥០១ មាត្រា៥០៣ មាត្រា

៥០៤ មាត្រា៥០៥ មាត្រា៥០៦ មាត្រា៥០៧ និង មាត្រា៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦) និងការធ្វើទារុណកម្ម (មាត្រា៥០០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦) បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤។

## មូលហេតុនៃសេចក្តីសម្រេច

យល់ឃើញថា ដូចដែលមានចង្អុលបង្ហាញដោយសហព្រះរាជអាជ្ញាខ្លួនឯងនៅក្នុងពាក្យសុំរបស់ខ្លួន (កថាខណ្ឌ៧) អង្គហេតុដែលទាក់ទងនឹងបទមនុស្សឃាត និងការធ្វើទារុណកម្ម ដែលមានចែងនៅក្នុងមាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានស៊ើបអង្កេតរួចហើយនៅក្នុងក្របខណ្ឌនៃការស៊ើបសួរទាក់ទងនឹងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើសន្និសញ្ញាទីក្រុងហ្សឺណែវ។

យល់ឃើញថាដីកាដំណោះស្រាយ នឹងបញ្ជាក់ពីបទល្មើសជាក់លាក់ដែលត្រូវកំណត់យកសម្រាប់ឧក្រិដ្ឋកម្មនិមួយៗដែលបានប្រព្រឹត្តនៅស២១ ដែលត្រូវចោទប្រកាន់លើជនត្រូវចោទ និង យល់ឃើញថា នៅក្នុងដំណាក់កាលនេះ ដោយមិនមានភស្តុតាងអ្វីថ្មីនោះ មិនត្រូវបញ្ជាឲ្យមានការបើកការស៊ើបសួរឡើងវិញជាថ្មី ដើម្បីធ្វើការដាក់ឲ្យនៅក្រោមការពិនិត្យបន្ថែមនោះទេ។

### ហេតុដូច្នេះ

សម្រេចមិនបំពេញកិច្ចស៊ើបសួរដែលបានស្នើសុំនេះទេ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**

**Co-juges d'instruction**



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.